រាជបណ្ឌិត្យសភាកម្ពុជា

# «វិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១»

## - ភាគទី៤ -




អត្ថបទចងក្រងដោយ៖ លោកស្រី ស៊ិន ច័ន្ទអមរា
មន្ត្រីលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា

-២០១៩-

# វិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១

## (ភាគទី៤)

### អត្ថបទចងក្រងដោយៈ

លោកស្រី ស៊ន ច័ន្ទអមរា មន្រ្តីលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ
នៃរាជបណ្ឌិត្យសភាកម្ពុជា




**ផែនទីបង្ហាញអំពីសមរភូមិក្តៅ និងតំបន់ខ្ទេចខ្ទាំ នៅប្រទេសបារាំង ក្នុងសង្គ្រាមលោកលើកទី១ នៅឆ្នាំ១៩១៤-១៩១៨។ ទាហានស្ម័គ្រចិត្តខ្មែរ ត្រូវបានបញ្ជូនទៅកាន់គោលដៅខ្លះនៃសមរភូមិក្តៅនោះ ដែលដៅដោយពណ៌ក្រហមនៅលើផែនទី**[1]

សូមរំឭកថានៅក្នុងភាគទី១ យើងបានបង្ហាញអំពីកិច្ចសហការបារាំង-ខ្មែរខាងកងទ័ពជើងគោក នៅចុងសតវត្សរ៍ទី១៩ និងក្នុងសង្គ្រាមលោកលើកទី១ ដែលមានយុទ្ធនាការជ្រើសរើសទាហានស្ម័គ្រចិត្តខ្មែរជាច្រើនរយនាក់ ឱ្យទៅជួយច្បាំងនៅប្រទេសបារាំង។ ចំណែកនៅក្នុងភាគទី២ មានការបង្ហាញអំពីលិខិតរបស់ឧញ្ញាវាំងជូនទៅកាន់លោករេស៊ីដង់ជាន់ខ្ពស់បារាំងនៅឆ្នាំ១៩១៦ ស្តីអំពីព្រះរាជដំណើរ២លើករបស់ព្រះបាទស៊ីសុវត្ថិ ក្នុងការជ្រើសរើសអ្នកស្ម័គ្រចិត្តនៅក្នុងខេត្តព្រៃវែង និងស្វាយរៀង។ រីឯភាគទី

[1] Front de l'Ouest (Première Guerre mondiale)។

៣ បង្ហាញអំពីព្រះរាជឱង្ការរបស់ព្រះបាទស៊ីសុវត្ថិទៅកាន់រាជវង្សានុវង្ស អង្គអគ្គមហាសេនាបតី នាម៉ឺនសព្វមុខមន្ត្រីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងប្រជារាស្ត្រគ្រប់សាសន៍ឱ្យបានដឹងអំពីគុណបំណាច់របស់ប្រទេសបារាំងមកលើប្រទេសកម្ពុជា ដែលត្រូវជួយបារាំងវិញនៅក្នុងចម្បាំងប្រឆាំងនឹងអាល្លឺម៉ង់នេះ។

ភាគទី៤ ដែលជាប្រធានបទសំខាន់របស់យើងនឹងផ្តោតទៅលើបណ្តាចំណុចដែលមានការពាក់ព័ន្ធនឹងវិមានរំឭកដល់អ្នកស្លាប់នៅក្នុងសង្គ្រាមលោកលើកទី១នេះតែម្តង ដោយចាប់ផ្តើមពីមូលហេតុនៃការសាងសង់ដែលមានខ្លឹមសារដូចតទៅ៖

## ៤-វិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១


រាជកិច្ចរាជការ ៥៩

សេចក្ដីក្រោរាជ្ញារ

បុណ្យឆ្លងវិមាន

ដែរសានកន្ត្រែនកម្ពុជាធិបត្តី

ជាទីរំពឹកដល់អស់អ្នក ដែលទទួលអនិច្ចកម្ម ក្នុងចំបាំងធំ

(ពីឆ្នាំ ១៩១៤ ដល់ឆ្នាំ ១៩១៨)

ខាងលើនេះជាប្រភពឯកសារដើម នៅក្នុងរាជកិច្ចរាជការ ឆ្នាំ១៩២៥

### ៤-១-មូលហេតុនៃការសាងសង់វិមាន

សម្រាប់ភាគទី៤នេះ អត្ថបទរបស់យើងផ្អែកលើប្រភពឯកសារមានចំណងជើងថា «បុណ្យឆ្លងវិមានដែលសាងក្នុងក្រុងកម្ពុជាធិបតី» ជាទីរំឭកដល់អស់អ្នក ដែលទទួលអនិច្ចកម្ម ក្នុងចំបាំងធំ(ពីឆ្នាំ១៩១៤ដល់ឆ្នាំ១៩១៨)[2] ដែលមានខ្លឹមសារដើមនិងកែសម្រួលដូចតទៅៈ

ក្នុងដើមខែសីហាឆ្នាំ១៩១៤ មានដំណឹងផ្ទួនៗ មកដល់ប្រទេសឥណ្ឌូចិន ថាត្រូវធ្វើកំណែនទ័ពជាឱរ៉ាល់[3] ដោយស្រុកមានចម្បាំងនោះ ក្នុងនគរក្រុងកម្ពុជាទាំងមូលក៏ញាប់ញ័ររន្ធត់អស់ទាំងពោះពុង ហើយក្រហល់ក្រហាយចង់សម្តែងដោយបែបផ្សេងៗ។ ក្រៅពីបានឱ្យឃើញថាខ្លួនមានចិត្តសុចរិតស្មោះត្រង់និងនគរអាណាព្យាបាល គឺនគរបារាំងសែស ដែលក្នុងគ្រានោះមានសេចក្តីក្រីក្រជាខ្លាំង ហើយត្រូវការឱ្យមានសេចក្តីមេត្រីទាំងប៉ុន្មានៗទៅជួយយកអាសា។

ឯជាតិបារាំងសែសនឹកចាំពុំភ្លេច នូវសេចក្តីដែលកូនចៅបណ្តារាស្ត្រខ្មែរដើម(ខ្មែរម្ចាស់ស្រុក) សម្តែងឱ្យឃើញចិត្តគំនិតយ៉ាងប្រពៃក្នុងគ្រានោះ ដែលជាគ្រាគួរឱ្យចាំនៅក្នុងចិត្តជាដើម។ ក្នុងព្រះនគរទាំងមូល តាំងពីថ្នាក់កំពូល រហូតទៅដល់ស្រុកស្រែចម្ការ មនុស្សមានចិត្តគំនិតដូចគ្នាទាំងអស់ គឺហ៊ានពលីជីវិតជូនប្រទេសជាតិ និងមានទម្លាប់ពីសម័យបុរាណចេះយកអាសាគ្នា ដោយគ្មានគិតប្រាថ្នាយកសគុណប្រយោជន៍អ្វីទេ។ ព្រះបាទស៊ីសុវត្ថិបានបញ្ជូន អ្នកអង្គម្ចាស់មួយចំនួនទៅច្បាំងនៅប្រទេសបារាំង។ ដោយអ្នកអង្គម្ចាស់២អង្គសុគត់នៅក្នុងចម្បាំងនោះ ប្រជារាស្ត្រខ្មែរជាច្រើននាក់បានយកតម្រាប់តាមដោយស្ម័គ្រចិត្តចូលធ្វើទាហានប្រយុទ្ធនិងទាហានជាងនៅក្នុងសង្គ្រាមនោះដែរ[4]។

តាំងពីគ្រានោះតរៀងដរាបមកដល់រួចចម្បាំង នៅវេលាដែលកងទ័ពយើងអន់ទន់ជាខ្លាំងក្តី ឬនៅវេលាដែលយើងមានជ័យជម្នះក្តី នោះនគរក្រុងកម្ពុជាចេះតែទុកចិត្តជាដរាបថា ព្រះនគរបារាំងសែសនឹងមានជ័យជម្នះ ផ្ចាញ់សត្រូវបច្ចាមិត្តមិនខាន។ ក្នុងពេលដែលមើលឃើញថាអាល្លឺម៉ង់ទំនងជាឈ្នះសង្គ្រាមម្តងៗនោះ មានប្រទេសចំណុះបារាំងខ្លះ លែងចង់នៅក្រោមបារាំងតទៅទៀតដែលជាហេតុនាំឱ្យបារាំងធ្វើការបង្ក្រាបដោយបង្ហូរឈាម។ ប៉ុន្តែនៅឯប្រទេសកម្ពុជាវិញពុំមានបញ្ហាបែបនោះឡើយ។ ក្នុងរវាង៥០ខែដែលមានចម្បាំងរាំងជល់រវាងបារាំងនិងអាល្លឺម៉ង់នោះ នគរក្រុងកម្ពុជាខិតខំបង្កបង្កើនផលស្រូវ ពោត និងគ្រាប់ល្ហុងខ្មែរ ដែលប្រទេសបារាំងត្រូវការ។ លទ្ធផលល្អនេះបានមកពីភាពវៃឆ្លាត របស់មន្ត្រីគ្រប់គ្រងរាជ

[2] ប្រភពដើម: បុន្យ៍ឆ្លងវិមានដែរសាងក្នុងក្រុងក័ម្ពុជាធិប្តី, ជាទីរំឭកដល់អស់អ្នក ដែលទទួលអនិច្ចកម្ម ក្នុងចំបាំងធំ(ពីឆ្នាំ១៩១៤ដល់ឆ្នាំ១៩១៨), នៅក្នុងរាជកិច្ចរាជការ ឆ្នាំ១៩២៥, ចាប់ពីទំព័រ៥៩។

[3] កំណែនជាឱរ៉ាល់: កំណែនទូទៅ (Mobilisation générale/General mobilization)។

[4] តាមឯកសារបុន្យ៍ឆ្លងវិមានដែរសាងក្នុងក្រុងក័ម្ពុជាធិប្តីខាងលើនេះ អ្នកអង្គម្ចាស់២អង្គដែលបានសុគត់ក្នុងចម្បាំងនោះទំនងជាមានឈ្មោះឡេង ស៊ីសុវត្ថិ និង រ៉ាឌីណាវង្ស (នៅក្នុងបញ្ជីឈ្មោះអ្នកស្លាប់ជិត២០០នាក់ ដែលនឹងបញ្ជាក់នៅក្នុងអត្ថបទក្រោយ), រាជកិច្ចរាជការ ឆ្នាំ១៩២៥, ទំព័រ៧៧។

ការអាណាព្យាបាលបារាំង ដែលរក្សាបាននូវស្ថេរភាពក្នុងសង្គមកម្ពុជានាសម័យនោះ។ នៅក្នុងវេលាដែលបារាំងកំពុងច្បាំងនោះ ទាហានបារាំងទាំងប៉ុន្មានត្រូវយកចេញពីរោងទាហាន[5]ទៅស្ទាត់អស់។ បារាំងគ្មានអ្វីនឹងបង្ការឱ្យបានសេចក្ដីក្សេមក្សាន្តក្នុងស្រុកសោះឡើយ គឺបារាំងមានសង្ឃឹមតែសេចក្ដីសុចរិតស្មោះត្រង់ពីនគរដែលបារាំងទំនុកបម្រុង ដូចជានគរកម្ពុជាជាដើម។ សេចក្ដីសុចរិតទៀងត្រង់របស់ខ្មែរនោះ ត្រូវបានបង្ហាញយ៉ាងច្បាស់ នៅពេលដែលលោកម៉ារេសាល់«សុព»[6] (គឺលោកសេនាប្រមុខសុព) បានដើរឆ្លងកាត់ស្រុកខ្មែរពីជើងទៅត្បូង ពីកើតទៅលិច ពុំចាំបាច់មានមនុស្សជូនតាមផ្លូវឡើយ។ តែការនេះពុំគួរឆ្ងល់អ្វីទេ ត្បិតនគរក្រុងកម្ពុជា ជានគរដែលមានចិត្តគំនិតថ្លើងខ្ពស់ គិតឃើញថាក្នុងវេលាដែលមានកូនចៅទៅច្បាំងតយុទ្ធនឹងស្រុកអាល្លឺម៉ង់នៅក្នុងរូងដី និងនៅកណ្ដាលវាលភក់[7] ក្នុងនគរបារាំងសែសហើយនិងទៅធ្វើជាជាងយកចំណេះកម្លាំងទៅធ្វើការជួយយកអាសាប្រទេសបារាំង បើនាំបង្កើតចលាចលក្នុងទីនោះឡើងនោះទុកជាសេចក្ដីក្បត់អាប់ឱនខ្លាំងណាស់(ខ្លឹមសារដើម)។



**លោកសេនាប្រមុខ Joseph Joffre (១៨៥២-១៩៣១) បានកាន់តំណែងជាអគ្គបញ្ជាការកងទ័ពបារាំង នៅរណសិរ្សខាងលិច ពីពេលចាប់ផ្ដើមសង្គ្រាមលោកលើកទី១ដល់ដំណាច់ឆ្នាំ១៩១៦[8]។**

[5] រោងទាហាន គឺបន្ទាយទាហាន។ ពាក្យរោងនេះនៅមានប្រើរហូតមកដល់សព្វថ្ងៃមួយចំនួនដូចជាពាក្យ រោងបុណ្យ, រោងការ, រោងល្ខោន និងរោងភាពយន្ត ជាដើម។

[6] លោកម៉ារេសាល់«សុព» (Maréchal Joffre) គឺលោកសេនាប្រមុខឈ្មោះ Joffre។

[7] គឺនៅសមរភូមិក្ដៅដូចមានដៅនៅលើផែនទីខាងលើស្រាប់។

[8]( https://www.history.com/topics/world-war-i/joseph-joffre)

ក្នុងចំនួនជំទង់អ្នកស្រុកអាយ[9] ដែលចូលទៅក្នុងកងទ័ពនិងចូលធ្វើជាជាងនោះមានចំនួនជាង ១៥០នាក់ ទទួលអនិច្ចកម្មនៅទីចម្បាំង ឬនៅទីទ័ពខាងក្រោយនៅប្រេបគូកនជាតិបារាំងសែស៣៣នាក់ ទៅពីស្រុកខ្មែរជាមួយគ្នា គឺទៅធ្វើការតែមួយនិងមានចិត្តគំនិតសង្ឃឹមទៅមុខបែបដូចគ្នា។

ដើម្បីនឹងតម្កើងនាក់ទាំង២០០នាក់ ដែលស៊ូបង់ជីវិតជាមួយគ្នាពុំមានភិតភ័យខ្លាចអ្វី ឱ្យបានតែយកអាសាព្រះមហានគរ[10]នោះ នគរក្រុងកម្ពុជាទាំងមូលដែលមានសេចក្តីកតញ្ញូនិងសេចក្តីកោតសសើរ ក៏បានសាងវិមានរូប១ដែរ នៅថ្ងៃទី១ ខែមីនានេះ មានបណ្តាជនគ្រប់សាសន៍ក្នុងព្រះនគរចូលមកគ្រប់គ្នា សម្រួមចិត្តគិតខាងផ្លូវធម៌។

(សូមរង់ចាំអានភាគបន្ត...)

[9] ជំទង់អ្នកស្រុកអាយ គឺទាហានស្ម័គ្រចិត្តខ្មែរ។

[10] ព្រះមហានគរ គឺប្រទេសបារាំង។